For information only. Please fill in the English version.

# អនុស្សរណៈនៃការយោគយល់

## រវាង

### គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* និង (ឈ្មោះរោងចក្រ)..........................................................

១. គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (ពីមុនត្រូវបានគេស្គាល់ថាជា គំរោងកែលំអល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា ដែលជាផ្នែកមួយរបស់កម្មវិធីអង្គការពលកម្មអន្តរជាតិ) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០១ ក្នុងគោលបំណងជួយដល់វិស័យកាត់ដេរនៅកម្ពុជាឱ្យសំរេចបាន និងបន្តការកែលំអឱ្យបានប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារ ។ គំរោងនេះ បានដំណើរការលូតលាស់ទៅបាន ដោយសារមានកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងកម្ពុជាដែលក្នុងនោះបានចែងពីការផ្តល់ប្រព័ន្ធកូតានាំចេញមុខទំនិញសំលៀកបំពាក់ជាក់លាក់ពីប្រទេសកម្ពុជាទៅកាន់សហរដ្ឋអាមេរិក ។ ក្រោមកិច្ចព្រមព្រៀងនេះ សហរដ្ឋអាមេរិក បានផ្តល់រង្វាន់លើការនាំចេញចំពោះកម្ពុជា ដ៏រាបណាប្រទេសកម្ពុជាធ្វើការកែលំអល័ក្ខខ័ណ្ឌការងារឱ្យបានប្រសើរ ។

២. ដើម្បីអាចវាស់វែង និងធានាដល់ល័ក្ខខ័ណ្ឌការងារ គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដោយមានការចូលរួមសហការពីរោងចក្រកាត់ដេរនានានៅកម្ពុជា បានធ្វើការសង្កេតឃ្លាំមើល និងរាយការណ៍ពីល័ក្ខខ័ណ្ឌការងារនៅតាមរោងចក្រកាត់ដេរទាំងនោះ ឱ្យទៅតាមបទដ្ឋានជាតិ និងអន្តរជាតិ និងបានជួយដល់រោងចក្រទាំងនោះក្នុងការបង្កើននូវផលិតភាព និងសហការជាមួយរាជរដ្ឋាភិបាល និងអ្នកបញ្ជាទិញអន្តរជាតិ ដើម្បីធានាឱ្យប្រាកដថា មានវដ្តនៃការកែលំអល័ក្ខខ័ណ្ឌការងារមួយប្រកបដោយតម្លាភាព និងហ្មត់ចត់ ។

៣. កិច្ចព្រមព្រៀងពាណិជ្ជកម្មកម្ពុជា សហរដ្ឋអាមេរិក បានបញ្ចប់នៅដំណាច់ឆ្នាំ ២០០៤ ដែលដូចគ្នាទៅនឹងកិច្ចព្រមព្រៀងពហុសរសៃអំបោះផងដែរ ដែលបានដាក់កំហិតនៃការនាំចូលពីប្រទេសដែលមានតំលៃផលិតសំលៀកបំពាក់ទាបដូចជាប្រទេសចិន និងឥណ្ឌា ទៅកាន់សហរដ្ឋអាមេរិក និងបណ្តាប្រទេសសហភាពអឺរ៉ុប ។ ជាមួយអណត្តិនៃកិច្ចព្រមព្រៀងទាំងនេះ ប្រទេសកម្ពុជាត្រូវប្រឈមទៅនឹងការប្រកួតប្រជែងក្នុងថ្នាក់ពិភពលោក ។ ដើម្បីរក្សាបាននូវការប្រកួតនេះ រោងចក្រកាត់ដេរទាំងឡាយនៅកម្ពុជា បច្ចុប្បន្នចាំបាច់ត្រូវធ្វើខ្លួនឱ្យលេចធ្លោឡើងនៅលើទីផ្សារ ។

៤. ប្រទេសកម្ពុជា បានធ្វើខ្លួនឱ្យលេចធ្លោក្នុងកិរិតមួយដែលមានល័ក្ខខ័ណ្ឌការងារកាន់តែប្រសើរឡើងជាលំដាប់ ព្រមទាំងបានសំរួលដល់ការទទួលបាន និងការផ្តល់ព័តិមានដែលអាចជឿទុកចិត្តបានអំពីការគោរពច្បាប់ការងារ ទៅតាមបទដ្ឋានជាតិ និងអន្តរជាតិរបស់រោងចក្រ ។ គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នឹងធ្វើការស្វះស្វែងដើម្បីកសាងនូវភាពរីកចំរើនដែលមានរួចស្រេចហើយ នៅតាមផ្នែកទាំងពីរនេះ ប៉ុន្តែកិច្ចសហប្រតិបត្តិការរបស់រោងចក្រកាត់ដេរនៅកម្ពុជា ក៏ជាគន្លឹះសំខាន់ជួយដល់ការធ្វើឱ្យគំរោងបន្តបានជោគជ័យផងដែរ ។

៥. អនុស្សារណៈនៃការយោគយល់គ្នា និងទំរង់ចុះឈ្មោះដែលមានភ្ជាប់មកជាមួយនេះ ផ្តល់ជាក្របខ័ណ្ឌការងារមួយសំរាប់កិច្ចសហការរវាងគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* និងរោងចក្រកាត់ដេរនិមួយៗ ដែលមានបំណងក្នុងការចូលរួមការងារជាមួយនឹងគំរោង ។

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel: (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax: (+855) 23 212 903
E-mail: betterfactories@ilo.org
Website: www.betterfactories.org/ilo

៦. តាមរយៈការចុះហត្ថលេខាលើអនុស្សារណៈនេះ និងការផ្តល់ព័ត៌មានដែលជាតំរូវការសំរាប់ការចុះឈ្មោះ (ឈ្មោះរោងចក្រ)..............................................................................................បានព្រមព្រៀងក្នុងការ :

ក. ផ្តល់សិទ្ធិពេញលេញដល់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ក្នុងការធ្វើការងារអង្កេតឃ្លាំមើលចំពោះអគារនានារបស់រោងចក្ររួមទាំងតំបន់ជុំវិញ (ដូចជាកន្លែងស្នាក់នៅ) ក៏ដូចជាចំពោះរាល់ឯកសារពាក់ព័ន្ធនានាដែលតំរូវដល់ការងារអង្កេតឃ្លាំមើល ដើម្បីបំពេញសកម្មភាពការងាររបស់គំរោង ។

ខ. អនុញ្ញាតដល់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ក្នុងការអង្កេតឃ្លាំមើល ធ្វើការប្រាស្រ័យទាក់ទងដោយសេរីជាមួយប្រតិភូបុគ្គលិក តំណាងសហជីព កម្មករនិយោជិត និងអ្នកពាក់ព័ន្ធនានាទាំងនៅខាងក្នុង និងខាងក្រៅបរិវេណរោងចក្រ ។

គ. ផ្តល់លទ្ធភាពដូចមានបញ្ជាក់ក្នុងវាក្យខ័ណ្ឌ (ក) និង (ខ) ខាងលើ ទាំងក្នុងអំឡុងពេលចុះអង្កេតឃ្លាំមើលរោងចក្រដោយមានការជូនដំណឹង និងដោយគ្មានការជូនដំណឹងជាមុន ។

ឃ. បញ្ឈប់ ឬលប់ចោលការធ្វើសកម្មភាពណាមួយ ដែលបង្កការរាំងស្ទះដល់ដំណើរការអង្កេតឃ្លាំមើលរបស់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ។

ង. កែលំអល័ក្ខខ័ណ្ឌការងារឱ្យបានកាន់តែប្រសើរ ។

តាមរយៈការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នានេះ គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* យល់ព្រមក្នុងការ :

ក. ប្រតិបត្តិនូវប្រព័ន្ធអង្កេតឃ្លាំមើលដោយយោងទៅតាម ឧបសម្ព័ន្ធ ១ ដោយមានការទទួលខុសត្រូវចំពោះរាល់អនុសាសន៍ដែលទទួលបានពីគណៈកម្មការប្រឹក្សាគំរោង ។

ខ. អនុវត្តការងារចុះអង្កេតឃ្លាំមើលដោយត្រឹមត្រូវ និងមិនលំអៀង ។

គ. កាត់បន្ថយការរំខាននានាដល់ការងារប្រតិបត្តិការរោងចក្រក្នុងអំឡុងពេលចុះធ្វើការអង្កេត

ឃ. រក្សាការសម្ងាត់ចំពោះព័ត៌មានផ្នែកពាណិជ្ជកម្មសំខាន់ៗទាក់ទងនឹងប្រតិបត្តិការជំនួញ ដែលព័ត៌មាននោះមិនមានពាក់ព័ន្ធដល់បទដ្ឋានស្តីពីកម្លាំងពលកម្មស្នូល ឬដល់ច្បាប់ការងារនៅកម្ពុជា ។

ង. ពិចារណាដោយស្មោះត្រង់ចំពោះរាល់ការចោទប្រកាន់ដោយគ្មានភស្តុតាងត្រឹមត្រូវ ដែលគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ធ្វើការអង្កេតឃ្លាំមើល ក្នុងដំណើរការប្រតិបត្តិការងាររបស់ខ្លួន ។

ច. ក្នុងករណីដែលការបកស្រាយទៅលើអនុស្សារណៈនៃការយោគយល់គ្នានេះមិនមានការឯកភាពគ្នាទេនោះ ភាគីទាំងពីរ ត្រូវខិតខំព្យាយាមស្វែងយល់គ្នាដោយស្មោះត្រង់ឱ្យបានដល់ចំណុចរួមមួយ ។ ហើយក្នុងករណីដែលនៅតែមិនអាចឯកភាពគ្នាបាននោះ ត្រូវដាក់បញ្ហានេះជូនទៅអាជ្ញាកណ្តាលក្នុងការដោះស្រាយវិញ ។

| | |
|---|---|
| តំណាងរោងចក្រកាត់ដេរ | តំណាងគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* |
| ឈ្មោះ | ឈ្មោះ |
| កាលបរិច្ឆេទ | កាលបរិច្ឆេទ |

១៣ កញ្ញា ២០០៥

# ឧបសម្ព័ន្ធ ១
# ដំណើរការអង្កេតឃ្លាំមើលរោងចក្រកាត់ដេរ
## គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*

## ១. ប្រវត្តិ

គោលបំណងមួយរបស់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* គឺដើម្បីធានាថា រោងចក្រកាត់ដេរនៅក្នុងប្រទេសអនុវត្តទៅតាមបទដ្ឋានពលកម្មដែលទទួលស្គាល់ជាអន្តរជាតិ និងទៅតាមច្បាប់ការងារនៅកម្ពុជា ។ គំរោងនេះបានបង្កើតនូវប្រព័ន្ធឃ្លាំមើលឯករាជ្យមួយដែលត្រូវបានរៀបចំឡើងដើម្បីចងក្រងជាព័ត៌មានមួយ ដែលអាចជឿទុកចិត្តបានស្តីពីល័ក្ខខ័ណ្ឌការងារដែលបានចូលរួមធ្វើនៅតាមបណ្តារោងចក្រ ។ ការឃ្លាំមើលនេះត្រូវបានដឹកនាំដោយអ្នកឃ្លាំមើលដែលត្រូវបានបង្កើតឡើង និងទទួលបានការបណ្តុះបណ្តាលដោយគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ហើយដែលត្រូវធ្វើការងារទៅតាម ការដឹកនាំរបស់ជំនួយការកម្មវិធី និងប្រធានទីប្រឹក្សាបច្ចេកទេស ។ គណៈកម្មការប្រឹក្សាគំរោង ធ្វើការពិភាក្សាអំពីមុខងារ នៃប្រព័ន្ធឃ្លាំមើល និងផ្តល់ជាការណែនាំព្រមទាំងធ្វើការវាយតម្លៃ ។

គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដែលជាប្រព័ន្ធគ្រប់គ្រងតាមរយៈកុំព្យូទ័រសំរាប់ការងារប្រមូល រក្សាទុក និងវិភាគទិន្នន័យ ។ ប្រព័ន្ធគ្រប់គ្រងព័ត៌មាននេះជួយដល់អ្នកឃ្លាំមើលក្នុងការរក្សាទុកព័ត៌មានដែលពួកគាត់បានប្រមូលក្នុងអំឡុងពេលចុះធ្វើការឃ្លាំមើលដោយផ្ទាល់តាមរោងចក្រទៅក្នុងកុំព្យូទ័រយួរដៃ ដែលខ្លួនបានរៀបចំជាស្រេចសំរាប់ការប្រមូលប្រភេទទិន្នន័យ (ជាប្រភេទតារាង) ។

## ២. ដំណើរការការងារឃ្លាំមើល

២.១ ការចុះបញ្ជីដោយស្ម័គ្រចិត្តជាមួយគំរោងតាមរយៈផ្តល់ការបំពេញបែបបទ និងចុះហត្ថលេខា មានអមជាមួយឯកសារពាក់ព័ន្ធនានាដល់ការិយាល័យគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៅភ្នំពេញ ។ តាមរយៈការចុះបញ្ជិកាជាមួយគំរោង រោងចក្រយល់ព្រមឱ្យអ្នកឃ្លាំមើលរបស់គំរោង ចុះទៅត្រួតពិនិត្យអង្កេតទាំងមានការជូនដំណឹងជាមុន និងមិនមានការជូនដំណឹងជាមុន ។

២.២ គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានអ្នកឃ្លាំមើល ដែលជាអ្នកត្រូវចុះទៅធ្វើការត្រួតពិនិត្យអង្កេតនៅតាមរោងចក្រជាក្រុមដោយមានគ្នា ២ នាក់ ។ គ្រប់អ្នកឃ្លាំមើលទាំងអស់ សុទ្ធតែទទួលបាននូវការបណ្តុះបណ្តាលស្តីពីបទដ្ឋានការងារជាតិ និងអន្តរជាតិ និងបច្ចេកទេសសំរាប់ធ្វើអធិការកិច្ច ។

២.៣ ក្រុមអ្នកឃ្លាំមើលធ្វើការងារដូចតទៅ :

- ជំនួយការកម្មវិធីរៀបចំកាលវិភាគកម្មវិធីចុះឃ្លាំមើល ដោយប្រើប្រាស់ព័ត៌មានដែលបង្កើតឡើងដោយប្រព័ន្ធគ្រប់គ្រងព័ត៌មាន ។
- អ្នកឃ្លាំមើលចុះធ្វើការងារឃ្លាំមើលរបស់ខ្លួន ដោយអាចពិភាក្សាជាមួយថ្នាក់គ្រប់គ្រង កម្មករនិយោជិត ប្រតិភូបុគ្គលិក និងប្រធានសហជីព ចុះធ្វើការងារអង្កេតអំពីល័ក្ខខ័ណ្ឌក្នុងរោងចក្រ ប្រមូល និងត្រួតពិនិត្យមើលឯកសារនានា ។

- អ្នកឃ្លាំមើលប្រើប្រាស់តារាងដែលបានរៀបចំជាមុនក្នុងកុំព្យូទ័ររបស់ខ្លួន ដើម្បីកត់ត្រាលទ្ធផលដែលបានរកឃើញក្នុងពេលចុះធ្វើការក្នុងរោងចក្រ ។ ការប្រើប្រាស់តារាងដែលបានរៀបចំជាមុនក្នុងកុំព្យូទ័រ ជួយជំរុញអ្នកឃ្លាំមើលឱ្យបំពេញរបាយការណ៍បានរហ័ស និងត្រឹមត្រូវ ។
- ច្បាប់ថតចម្លងតារាងបើកប្រៀវត្សរ៍ និងព័ត៌មានស្តីពីចំនួនម៉ោងធ្វើការ ចាំបាច់ត្រូវផ្តល់ឱ្យអ្នកឃ្លាំមើលនៅថ្ងៃដែលចុះទៅធ្វើការផ្ទាល់ ។ ឯកសារបន្ថែមដែលជាច្បាប់ថតចម្លងស្នើសុំដោយអ្នកឃ្លាំមើល ត្រូវបានទុកពេលឱ្យរោងចក្ររយៈ ពេល ១ សប្តាហ៍ ដើម្បីផ្តល់ជូនដល់អ្នកឃ្លាំមើលក្នុងអំឡុងពេលចុះធ្វើការងារ ។
- អ្នកឃ្លាំមើលបំពេញរបាយការណ៍ឃ្លាំមើលរបស់ខ្លួន នៅពេលដែលទទួលបានរាល់ឯកសារដែលខ្លួនត្រូវការហើយ ឬនៅពេលវេលាណាមួយ ដែលខ្លួនបានផ្តល់ឱ្យរោងចក្រដើម្បីផ្តល់ឯកសារឱ្យខ្លួន ។
- អ្នកឃ្លាំមើលដាក់របាយការណ៍របស់ខ្លួន ជូនដល់ប្រធានទីប្រឹក្សាបច្ចេកទេសសំរាប់សុំការយល់ព្រម ។
- របាយការណ៍ដែលបានបញ្ចប់ និងទទួលបានការយល់ព្រមហើយត្រូវដាក់ទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាន ។
- អ្នកគ្រប់គ្រងនៅតាមរោងចក្រ ត្រូវបានជូនដំណឹងតាមអ៊ីម៉េល ស្តីអំពីរបាយការណ៍ថ្មីដែលអាចមើលបាន[១] ។
- ថ្នាក់គ្រប់គ្រង អាចទទួលបានរបាយការណ៍ តាមរយៈការចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាន បើកវេបសាយរបស់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ims.betterfactories.org និងតំរូវឱ្យវាយពាក្យ សម្ងាត់ដើម្បីអាចចូលទៅមើលរបាយការណ៍រោងចក្របាន ។

២.៤ បញ្ជីត្រួតពិនិត្យផ្ទៀងផ្ទាត់ដែលមានការឯកភាពយល់ព្រមរួច ពីគណៈកម្មការប្រឹក្សាគំរោង កំណត់បញ្ហាដែលមានក្នុងអំឡុងពេលចុះធ្វើការឃ្លាំមើល ហើយដែលរួមមាន :

*សិទ្ធិជាមូលដ្ឋានរបស់កម្មករ*

- រួចផុតពីពលកម្មកុមារ
- រួចផុតពីការបង្ខំឱ្យធ្វើការងារ
- រួចផុតពីការប្រៀតប្រៀនខាងផ្លូវភេទ
- មានសេរីភាពក្នុងការចរចាររួម និងការបង្កើតជាសមាគមន៍
- មិនមានការរើសអើង

*ល័ក្ខខ័ណ្ឌការងារផ្សេងទៀត*

- ប្រាក់ឈ្នួល
- ថិរវេលាធ្វើការ
- ការឈប់សំរាក
- សុវត្ថិភាព និងសុខភាពការងារ
- ទំនាក់ទំនងការងារ

អ្នកឃ្លាំមើលក៏បានកត់ត្រាកំរិតនៃកិច្ចសហការពីសំណាក់អ្នកគ្រប់គ្រងក្នុងពេលដែលខ្លួនចុះទៅរោងចក្រ ។

---

[១] រោងចក្រដែលមិនមានប្រើប្រាស់អ៊ីម៉េល ឬវេបសាយ អាចទទួលបានរបាយការណ៍ឃ្លាំមើលរោងចក្ររបស់ខ្លួន តាមរយៈការផ្តល់ជូនដល់រោងចក្រដោយផ្ទាល់ ។

២.៥ សូចនាករសំរាប់បង្ហាញអំពីសេរីភាពក្នុងការចរចារួម និងការបង្កើតសមាគមន៍ ជាពិសេសផ្តោតទៅលើដំណើរការដែលកម្មករនិយោជិត អនុវត្តសិទ្ធិទាំងនេះនៅតាមកន្លែងធ្វើការ ។ អ្នកឃ្លាំមើលអាចធ្វើជាសាក្សីក្នុងការបោះឆ្នោតជ្រើសរើសសហជីពពាណិជ្ជកម្ម ប្រតិភូបុគ្គលិក និងក្នុងពេលចរចារជាមួយសមូហភាព ។ ពួកគាត់ក៏អាចពិចារណាទៅលើការប្តឹងផ្តល់ តាមរយៈការបង្កឧបសគ្គដល់សកម្មភាពសហជីព ឬធ្វើការប្រឆាំង ចំពោះសកម្មភាពសហជីពដែលទាំងនេះជាការរំលោភលើច្បាប់ការងារនៅកម្ពុជា ។ ព័ត៌មាននេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នៃការឃ្លាំមើល ។

២.៦ អ្នកឃ្លាំមើលមិនមានអំណាចអនុវត្តច្បាប់ឡើយ ។ នេះគឺជាតួនាទីរបស់អ្នកធ្វើអធិការកិច្ចការងារដែលបានពីក្រសួងការងារ ។ តួនាទីរបស់ពួកគាត់ គឺធ្វើការផ្ទៀងផ្ទាត់ល័ក្ខខ័ណ្ឌនានានៅតាមរោងចក្រដែលបានចូលរួម រាយការណ៍ពីរោងចក្រ និងផ្តល់ព័ត៌មាន និងដំបូន្មានដើម្បីធ្វើឱ្យមានភាពប្រសើរឡើង ។ ប្រធានទីប្រឹក្សាបច្ចេកទេសត្រួតពិនិត្យលើការងារឃ្លាំមើល និងកម្មវិធីកែលំអ អនុម័តលើរបាយការណ៍ឃ្លាំមើល និងសហការជាមួយដៃគូការងារសង្គម ដើម្បីធានានិរន្តរភាពវដ្តនៃល័ក្ខខ័ណ្ឌការងារឱ្យបានប្រសើរឡើង ។

## ៣. ការរៀបចំកម្មវិធីចុះឃ្លាំមើល

គំរោង ព្យាយាមចុះឃ្លាំមើលរោងចក្រដែលបានចុះបញ្ជីយ៉ាងហោចណាស់ ២ដង ក្នុងមួយឆ្នាំ ។

## ៤. ដំណោះស្រាយវិវាទយោងទៅតាមរបាយការណ៍

ស្របពេលដែលប្រធានទីប្រឹក្សាបច្ចេកទេសអនុម័តព្រមព្រៀងលើការចេញរបាយការណ៍ហើយ ពេលនោះរបាយការណ៍អាចចែកចាយដល់រោងចក្របាន ។ រោងចក្រអាចធ្វើសំណើសុំដំបូន្មានពីអ្នកឃ្លាំមើល ដោយផ្តោតទៅលើបញ្ហាដែលបានកំណត់ក្នុងរបាយការណ៍ឃ្លាំមើល ។ រោងចក្រក៏អាចធ្វើការជំទាស់បដិសេធចំពោះអ្វីដែលរកឃើញក្នុងរបាយការណ៍ លើរោងចក្ររបស់ខ្លួនដែលដាក់តាមវេបសាយ ក្នុងរយៈពេល ២១ ថ្ងៃ (ថ្ងៃធ្វើការ) តាមរយៈការចូលទៅក្នុងវេបសាយប្រព័ន្ធគ្រប់គ្រងព័ត៌មាន របស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ims.betterfactories.org ។ ការបដិសេធនេះ នឹងត្រូវមើលឃើញដោយ អ្នកបញ្ជាទិញដែលត្រូវបានទទួលសិទ្ធិពីរោងចក្រក្នុងការមើលរបាយការណ៍ទាំងនោះ ។

## ៥. ការរាយការណ៍

គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ផ្តល់របាយការណ៍របស់រោងចក្រនិមួយៗ ក៏ដូចជារបាយការណ៍សំយោគ ជាភាសាខ្មែរ អង់គ្លេស ឬចិន ។ របាយការណ៍រោងចក្រនិមួយៗ រួមបញ្ចូលទាំងក្រាហ្វិក បង្ហាញពីវិឌ្ឍនភាពពីពេលមួយទៅមួយទៀត និងធ្វើការប្រៀបធៀបជាមួយមធ្យមភាគនៅក្នុងឧស្សាហកម្មនេះទាំងមូល ។ របាយការណ៍ស្តីពីល័ក្ខខ័ណ្ឌការងារនៅរោងចក្រក៏មានបញ្ចូលនូវសំណូមពរដែលផ្តោតលើបញ្ហាជាក់លាក់ដែលមិនបានអនុវត្តតាម ព្រមទាំងកត់ត្រានូវវិឌ្ឍនភាពនៃការអនុវត្តន៍សំណូមពរទាំងនេះ ។ របាយការណ៍ឯកជនរបស់រោងចក្រនិមួយៗ អាចផ្តល់ជូនបានតែចំពោះរោងចក្រខ្លួនប៉ុណ្ណោះ និងចំពោះអ្នកបញ្ជាទិញណា ដែលទទួលបានសិទ្ធិពីម្ចាស់រោងចក្រតាមរយៈសំណេរជាផ្លូវការរបស់រោងចក្រ (ឧទាហរណ៍ អ្នកបញ្ជាទិញ អ្នកផ្គត់ផ្គង់) ។

របាយការណ៍សំយោគ អាចទទួលបានជាសាធារណៈ និងរួមបញ្ចូលទាំងក្រាហ្វិកងាយៗ ដែលមានបង្ហាញពីវិឌ្ឍនភាពនៅតាមក្រុមរោងចក្រនិមួយៗ ដែលបានអនុវត្តទៅតាមល័ក្ខខ័ណ្ឌ បញ្ហាគន្លឹះរបស់ឧស្សាហកម្មរួម និងទិន្នន័យដែលផ្តោតលើចំនួនកម្មករដែលបានជួលនៅក្នុងរោងចក្រទាំងនោះ ។

# MEMORANDUM OF UNDERSTANDING

Between

*Better Factories Cambodia* and (name of factory) …..……………………………………

1. *Better Factories Cambodia* (formerly known as the ILO Garment Sector Project), was established in 2001 to help Cambodia's garment sector achieve and maintain improvements in working conditions. The project grew out of a trade agreement between the United States and Cambodia, which set an export quota for certain garments from Cambodia to the United States. Under the agreement, the US allocated bonus export entitlements to Cambodia, as long as the country made gains in improving working conditions.

2. In order to measure and ensure gains in working conditions, *Better Factories Cambodia*, in cooperation with participating Cambodian garment factories, has monitored and reported on working conditions according to national and international standards, helped factories to improve their productivity, and worked with the Government and international buyers to ensure a rigorous and transparent cycle of improvement.

3. The Cambodian-US trade agreement expired on 31 December 2004, as did a global Multi-Fibre Agreement (MFA), which had imposed limits on imports to the United States and the European Union countries from key low-cost manufacturing countries such as China and India. With the expiration of these agreements, Cambodia is subject to global competition. In order to remain competitive, Cambodian garment factories now must somehow distinguish themselves in the market.

4. Cambodia has set itself apart to some extent by continuously improving working conditions, and by facilitating access to reliable information regarding factory compliance with international and national labour standards. *Better Factories Cambodia* will seek to build upon the progress that already has been made in both of these areas, but the cooperation of Cambodia garment factories is critical to the project's continued success.

5. This memorandum of understanding and its attached registration form provide the framework for cooperation between *Better Factories Cambodia* and individual garment factories that wish to participate in the project.

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel: (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax: (+855) 23 212 903
E-mail: betterfactories@ilo.org

6. By signing this memorandum of understanding and providing the information required for registration, (factory name)………………………………………
agrees to:

a. provide full access to *Better Factories Cambodia* monitors to factory premises, including surrounding areas (such as dormitories), as well as to all relevant documentation required by monitors in order to perform their tasks;
b. allow *Better Factories Cambodia* monitors to freely interact with shop stewards, union representatives, factory workers and other relevant persons, both inside and outside factory premises;
c. provide access as specified under paragraphs a and b above during both announced and unannounced factory visits;
d. refrain from any acts or omissions that may hamper the ability of *Better Factories Cambodia* monitors to perform their tasks;
e. undertake to improve working conditions.

By signing this memorandum of understanding, *Better Factories Cambodia* agrees to:

a. execute the monitoring system in accordance with Annex 1, taking into account any future recommendations of the Project Advisory Committee;
b. carry out monitoring visits in a fair and objective manner;
c. attempt to minimize any disruption to factory operations during monitoring visits;
d. keep confidential basic commercial information regarding business operations that is not related to factory compliance with core labour standards or Cambodian labour law;
e. consider, in good faith, any allegation of misconduct by a *Better Factories Cambodia* monitor in the execution of his/her duties;

f. In case of any disagreement over the interpretation of the present memorandum of understanding, the parties shall make an effort, in good faith, to reach a common understanding. In the absence of such a common understanding, the matter shall be referred to a mutually agreed upon arbitrator.

| Garment factory representative | *Better Factories Cambodia* representative |
|---|---|
| Name: | Name: |
| Date: | Date: |

## ANNEX 1

## Garment Factory Monitoring Process
***Better Factories Cambodia***

---

### 1. Background

One goal of *Better Factories Cambodia* is to ensure that garment factories in Cambodia comply with internationally recognized core labour standards and the Labour Law of Cambodia. The project has developed an independent monitoring system designed to generate reliable information on working conditions in participating factories. Monitoring is conducted by monitors who are recruited and trained by *Better Factories Cambodia*, and who operate under the direction of the Programme Assistant and the Chief Technical Advisor (CTA). A Project Advisory Committee (PAC) discusses the functioning of the monitoring system and provides guidance and evaluation.

*Better Factories Cambodia* has developed an information management system (IMS), which is a computerized system for collecting, storing and analyzing data. The IMS enables monitors to store the information they collect during monitoring visits directly into laptops specifically designed to collect data (Tablet PCs).

### 2. How the monitoring process works

2.1 Factories voluntarily register with the project by providing a completed, signed registration form, with related documents, to the *Better Factories Cambodia* office in Phnom Penh, Cambodia. By registering with the project, factories agree to submit to unannounced and announced monitoring visits by project monitors.

2.2 *Better Factories Cambodia* employs monitors, who conduct monitoring visits in teams of 2. All monitors receive appropriate training on national and international labour standards and inspection techniques.

2.3 The monitoring teams work as follows:

- The Programme Assistant schedules monitoring visits, using information generated by the IMS.
- The monitors conduct monitoring visits, which may include discussions with management, workers, shop stewards, and union leaders; observation of factory conditions; and collection and review of documents.
- The monitors use Tablet PCs to record their findings during factory visits. The use of Tablet PCs enables monitors to complete reports quickly and accurately.
- A copy of the payroll and working hours information must be provided on the day of the visit. Factories are given one week to provide copies of any additional documents requested by monitors during the factory visit.

- Monitors complete monitoring reports upon receiving all necessary documents, or upon expiration of the time allotted for a factory to provide documents.
- Monitors present their reports to the CTA for approval.
- Finalized, approved reports are uploaded to the IMS.
- Factory management is notified by email that a new report is available.[1]
- Management can receive reports by logging onto the *Better Factories Cambodia* IMS website, at ims.betterfactories.org. A password is required to access factory reports.

2.4 A checklist approved by the Project Advisory Committee identifies the issues covered during monitoring visits, including the following:

***Basic worker rights:***
- Freedom from child labour
- Freedom from forced labor
- Freedom from sexual harassment
- Freedom of association and collective bargaining
- Non-discrimination

***Other working conditions:***
- Wages
- Hours of work
- Leave
- Occupational safety and health
- Labor relations

Monitors also record the level of cooperation by management during a factory visit.

2.5 The indicators for freedom of association and collective bargaining in particular, focus on the process of workers exercising these rights at the workplace. The monitors may witness trade union elections, shop steward elections, and collective bargaining sessions. They also consider any complaints by workers of interference in union activity or anti-union actions in violation of Cambodian labor law. This information is reflected in factory monitoring reports.

2.6 The monitors do not have law enforcement powers. This is the role of labour inspectors from the ministry of labour. Their role is to verify the conditions in participating factories, to report on them and to provide information and advice on improving compliance. The CTA oversees the monitoring and remediation programs, approves the monitoring reports, and works with the social partners to ensure a continuous cycle of improvement in working conditions.

[1] Factories that do not have access to email or the worldwide web may have their factory visit reports delivered to the factory.

## 3. Scheduling of visits

The project seeks to visit each participating factory at least twice per year.

## 4. Resolving Disputes Regarding Reports

Once the CTA has approved a monitoring report, the report is made available to the factory. Factories may request advice from monitors in addressing compliance issues identified in monitoring reports. Factories also can lodge objections to findings in their reports online within 21 working days, by logging onto the *Better Factories Cambodia* IMS website, at ims.betterfactories.org. Objections will be visible to buyers who have been granted access by factories to the reports.

## 5. Reporting

*Better Factories Cambodia* provides individual factory reports as well as synthesis reports in Khmer, Chinese or English. Individual factory reports include graphs tracking progress on compliance over time, and comparing this to the industry average. Factory reports also include suggestions to address specific non-compliance issues, and track progress implementing these suggestions. Individual factory reports are accessible only to the factory and to any buyers or others granted access in writing by the factory (e.g. buyers, vendors).

Synthesis reports are publicly available, and include, for example, easy-to-read graphs showing progress by individual factories on compliance, key industry-wide compliance issues, and data regarding the number of workers employed in garment factories.